# របាយការណ៍

# ស្តីពីយុទ្ធនាការចែកមុងជ្រលក់ថ្នាំដល់ប្រជាពលរដ្ឋ

# និងប្រជាជនចល័តដែលប្រឈមនឹងជំងឺគ្រុនចាញ់ ក្នុងខេត្តព្រះវិហារ

# ស្រុកជាំក្សាន្ត ថ្ងៃទី ១៧ ខែ កម្ភៈ ឆ្នាំ ២០១២

## ១. សង្ខេប:

ក្នុងក្របខ័ណ្ឌនៃការអនុវត្តន៏ផែនការយុទ្ធសាស្រ្តជាតិលុបបំបាត់ជំងឺគ្រុនចាញ់ឆ្នាំ ២០១១-២០២៥ របស់រាជរដ្ឋាភិបាលក្រសួងសុខាភិបាលបានដែលមានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្រ្ត និងបាណកសាស្រ្ត ដែលជាអ្នកអនុវត្តផ្ទាល់បាននិងកំពុងធ្វើយុទ្ធនាការចែកមុងជ្រលក់ថ្នាំដែលមានប្រសិទ្ធភាពយូរជូនដល់ប្រជាពលរដ្ឋ គោលដៅនិងប្រជាជនចល័តដែលរស់នៅក្នុងតំបន់ប្រឈមនឹងជំងឺគ្រុនចាញ់។ នេះយុទ្ធនាការដ៏ធំមួយដែលមិនធ្លាប់មានក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកដោយក្រសួងត្រូវចំណាយអស់ថវិកាប្រមាណ ជា ១៤.៤ លានដុល្លារអាមេរិក។ ដោយឡែកខេត្តព្រះវិហារបានប្រារពធ្វើយុទ្ធនាការចែកមុងជ្រលក់ថ្នាំជានិមិត្តរូបនៅភូមិធម្មជាតិ ឃុំកន្ទួត ស្រុកជាំក្សាន្ត នៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១២ ក្រោមអធិបតីភាពឯកឧត្តម **ស ថាវី** អភិបាលរងខេត្តព្រមទាំងលោក-លោកស្រីដែលជាមន្រ្តីនៃអាជ្ញាធរមូលដ្ឋាន និងមន្រ្តីរាជការនៃមន្ទីរសុខាភិបាលខេត្ត រួមទាំងប្រជាពលរដ្ឋចំនួនប្រមាណ ៤០០ នាក់ ដែលអញ្ជើញមកពី ភូមិធម្មជាតិ ឃុំកន្ទួត ស្រុកជាំក្សាន្ត ។ យុទ្ធនាការនេះនឹងត្រូវអនុវត្តន៏បន្តរហូតដល់ចុងខែ កុម្ភៈ ឆ្នាំ ២០១២ ខាងមុខនេះហើយមុងចំនួន ១៦២.៥០០ និងមុងអង្រឹងចំនួន ១៧.៨០០ នឹងត្រូវចែកជូនប្រជាពលរដ្ឋទាំងអស់ ក្នុងខេត្ត ។ ជាគោលការណ៏ប្រជាជនម្នាក់ត្រូវទទួលបានមុងមួយនិងថែមជូនមុងអង្រឹង១ថែមទៀតក្នុង១គ្រួសារ។

## ២. បេសកម្មនៅខេត្តព្រះវិហារ:

### ក. សមាសភាពក្រុមការងារដែលបានអញ្ជើញចូលរួមមាន:

- លោកវេជ្ជ. ហេង ពិសាល ប្រធាន
- លោកវេជ្ជ. ប៊ិន ប៉ូរ៉ាវង្ស សមាជិក
- លោកស្រីឱសថ. ម៉ម ប៉ូរ៉ាវ៉ាន់ សមាជិក
- លោក អ៊ុង វ៉ាន់ភូជា អ្នកបើកបរ

### ខ. សកម្មភាព:

ដើម្បីធានាថាដំណើរការនៃចែកមុងជ្រលក់ថ្នាំប្រព្រឹត្តទៅប្រកបដោយតម្លាភាពនិងសុក្រិត្យភាពក្រុមការងារបានចុះត្រួតពិនិត្យនូវរាល់សកម្មភាពត្រៀមរបស់មន្ត្រីនៅមូលដ្ឋាននៅតាមមណ្ឌលសុខភាពមួយចំនួនក្នុងខេត្តដោយផ្អែកលើចំណុចសំខាន់មួយចំនួន:

✍ *ពិនិត្យនិងផ្ទៀងផ្ទាត់នូវចំនួនសៀវភៅគ្រួសារ និងមុងជ្រលក់ថ្នាំ:*

- តើខេត្តទទួលបានសៀវភៅនិងមុងគ្រប់ចំនួនឬទេ?
- តើនៅពេលទទួលមុងមន្ត្រីទទួលបន្ទុកមានបានពិនិត្យឯកសារត្រឹមត្រូវឬទេ?
- តើខេត្តមានបានត្រៀមកន្លែងសំរាប់ទុកដាក់មុងឱ្យមានសុវត្ថិភាពឬទេ?

✍ *ដំណើរការបែងចែកមុង:*

- មានផែនការនិងតារាងបែងចែកមុងជ្រលក់ថ្នាំត្រូវបានរៀបចំហើយឬនៅ?
- បានធ្វើសំរង់ស្ថិតិប្រជាជនគោលដៅជាមួយអាជ្ញាធរមូលដ្ឋានដែរឬទេ?
- បានរៀបចំប្រជុំផ្សព្វផ្សាយព័ត៌មានដល់ក្រុមការងារពិសេសហើយឬនៅ?
- បានរៀបចំប្រជុំជាមួយមណ្ឌលសុខភាពនិងអ្នកស្ម័គ្រចិត្តភូមិដើម្បីរៀបចំផែនការសកម្មភាពចែកមុង:

- បង្កើតតារាងបែងចែកមុងជូនប្រជាជនគោលដៅនិងប្រជាជនចល័ត
- កំណត់ទីកន្លែងនិងកាលបរិច្ឆេទដើម្បីធ្វើការបែងចែកមុង
- រៀបចំផ្សព្វផ្សាយស្ពតខ្លីៗស្តីពីការអប់រំការប្រើប្រាស់មុងជ្រលក់ថ្នាំនិងស្ពតផ្សព្វផ្សាយពីការផ្តល់មុងដោយឥតគិតថ្លៃរបស់រាជរដ្ឋាភិបាលនិងការផ្តល់ជូននូវសៀវភៅគ្រួសារដោយឥតថ្លៃ។

ក្រុមការងារបានចុះពិនិត្យនិងតាមដានដំណើរការនៃការចែកមុងជ្រលក់ថ្នាំរយៈពេលយូរនេះនៅមណ្ឌលសុខភាពចំនួន០៥ ដែលស្ថិតនៅក្នុងស្រុកកំពង់ស្រឡៅ (មណ្ឌលសុខភាពកំពង់ស្រឡៅ) ស្រុករវាង (ម.ណ ឈ្នួន –ម.ណ ឆែប) តំបន់មុំបី (ម.ណ តេជោមរកត) និង ស្រុកជាំក្សាន្ត (ម.ណ សម្តេច ជា ស៊ីម)។

*គ- សកម្មភាពនៅថ្ងៃបើកយុទ្ធនាការចែកមុង:*

នៅព្រឹកថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១២ នៅមណ្ឌលសុខភាពសម្តេចមហាធម្មពោធិសាល **ជា ស៊ីម** យុទ្ធនាការចែកមុងជ្រលក់ថ្នាំរយៈពេលយូរត្រូវបានប្រារព្ធឡើងដោយមានការអញ្ជើញចូលរួមជាគណៈអធិបតីពី

- ឯកឧត្តម **ស ថាវី** អភិបាលរងខេត្តព្រះវិហារ
- លោកវេជ្ជ. **ហេង ពិសាល** អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ
- លោក **សុខ ហៃ** អភិបាលស្រុកជាំក្សាន្ត
- លោកស្រីវេជ្ជ. **ខូយ ប៊ុនថាន្នី** ប្រធានមន្ទីរសុខាភិបាលខេត្ត
- លោក-លោកស្រីមន្ត្រីរាជការនៃមន្ទីរសុខាភិបាលខេត្ត តំណាងអាជ្ញាធរមូលដ្ឋាន និង បងប្អូនប្រជាពលរដ្ឋយ៉ាងច្រើនកុះករ

បន្ទាប់ពីមតិស្វាគមន៍របស់លោក **សុខហៃ** អភិបាលស្រុកជាំក្សាន្ត លោកស្រីវេជ្ជ. **ខូយ ប៊ុនថាន្នី** ប្រធានមន្ទីរសុខាភិបាលខេត្តព្រះវិហារបានធ្វើរបាយការណ៍ជូនគណៈអធិបតីនិងអង្គពិធីទាំងមូល ពីស្ថានភាពទូទៅនៃប្រព័ន្ធសុខាភិបាលនៅក្នុងខេត្ត។

បន្ទាប់មកលោកស្រីប្រធានក៏បានជំរាបជូនអង្គពីធីផងដែរនូវចំនួនមុងជ្រលក់ថ្នាំដែលមន្ទីរសុខាភិបាលខេត្តទទួលបានពីមជ្ឈមណ្ឌល ជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ គឺមុងគ្រែ ចំនួន ១៦២.៥០០ និងមុងអង្រឹងចំនួន

១៧.៨០០នឹងត្រូវ ចែកជូនប្រជាពលរដ្ឋក្នុងខេត្តព្រះវិហារ ដោយធ្វើការបែងចែកបន្ទាប់ពីបានធ្វើសំរង់ស្ថិតិសៀវភៅគ្រួសាររួចរាល់ហើយនិងមកទទួលមុងតាមកាលបរិច្ឆេទដែលបានកំណត់ដោយអាជ្ញាធរមូលដ្ឋាន។

ជាគោលការណ៏ការធ្វើសំរង់ក្នុងសៀវភៅគ្រួសារ និង ការទទួលមុងគឺត្រូវធ្វើឡើងដោយឥតបង់ថ្លៃឬទទួលអំណោយអ្វីឡើយ។ លោកស្រីក៏បានបញ្ជាក់ផងដែរថាយុទ្ធនាការនេះមានរយៈពេលតែ ២០ ថ្ងៃប៉ុណ្ណោះ។

លោកវេជ្ជ. ហេង ពិសាល អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ ក៏បានផ្តល់នូវមតិសំណេះសំណាលនិងពាំនាំនូវសេចក្តីនឹករលឹកពីសំណាក់ឯកឧត្តមវេជ្ជ. **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាលជូនដល់លោក-លោកស្រីនៃមន្ទីរសុខាភិបាលខេត្តព្រះវិហារអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់និងបងប្អូនប្រជាពលរដ្ឋទាំងអស់ដែលរស់នៅក្នុងតំបន់ប្រឈមនឹងជំងឺគ្រុនចាញ់។ ឆ្លៀតក្នុងឱកាសនេះដែរ លោកវេជ្ជ. ហេង ពិសាល ក៏ជំរាបជូនគណៈអធិបតីនិងអ្នកចូលរួមទាំងអស់ពីយុទ្ធសាស្ត្រជាតិលុបបំបាត់ជំងឺគ្រុនចាញ់នៅឆ្នាំ ២០២៥ ដោយបានចែកជា៣ដំណាក់កាលសំខាន់ៗដូចខាងក្រោម :

- **ដំណាក់កាលទី១:** រយៈពេលខ្លី (ត្រឹមឆ្នាំ ២០១៥) ដើម្បីឆ្ពោះទៅរកការត្រៀមលុបបំបាត់ជំងឺគ្រុនចាញ់នៅក្នុងព្រះរាជាណាចក្រកម្ពុជាតាមរយៈការខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លាក្នុងការលុបបំបាត់មេរោគគ្រុនចាញ់ប្រភេទហ្វាល់ស៊ីប៉ារ៉ូម ដែលស៊ាំនឹងថ្នាំអាតេមីស៊ីនីន

- **ដំណាក់កាលទី២:** រយៈពេលមធ្យម (ឆ្នាំ ២០២០) ដើម្បីឆ្ពោះទៅរកការលុបបំបាត់ជំងឺគ្រុនចាញ់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយផ្តោតជាសំខាន់ដំបូងទៅលើមេរោគគ្រុនចាញ់ ប្រភេទហ្វាល់ស៊ីប៉ារ៉ូម និងធានា មិនឱ្យមានករណីស្លាប់ដោយសារជំងឺគ្រុនចាញ់។

- **ដំណាក់កាលទី៣:** រយៈពេលវែង (ត្រឹមឆ្នាំ ២០២៥) ដើម្បីសំរេចឱ្យបានដំណាក់កាលលុបបំបាត់ជំងឺគ្រុនចាញ់ទាំងស្រុងនៅក្នុងព្រះរាជាណាចក្រកម្ពុជា លើគ្រប់ទំរង់នៃមេរោគគ្រុនចាញ់។ លោកវេជ្ជបណ្ឌិតក៏បានបញ្ជាក់ជូនប្រជាពលរដ្ឋបន្ថែមផងដែរថា មុងទាំងអស់នេះជាអំណោយរបស់រាជរដ្ឋាភិបាល ដូច្នេះបងប្អូនទាំងអស់ត្រូវយកមុងទាំងនេះទៅប្រើឱ្យបាន ចំគោលដៅគឺត្រូវសំរាន្តក្នុងមុងជានិច្ច ដោយដាក់ជើងមុង ឱ្យបានត្រឹមត្រូវ ហើយត្រូវចេះថែរក្សា ជៀសវាងយកមុងទៅអូសត្រីឬធ្វើអ្វីផ្សេងដែលផ្ទុយនឹងការណែនាំរបស់មន្ត្រីសុខាភិបាល។ បន្ទាប់ពីចំណាប់អារម្មណ៏របស់លោកវេជ្ជបណ្ឌិត ហេង ពិសាល រួចមកឯកឧត្តម **ស ថាវី** អភិបាលរងខេត្តព្រះវិហារក៏បានមានមតិសំណេះសំណាលជាមួយបងប្អូនប្រជា ពលរដ្ឋដែលបានអញ្ជើញមកចូលរួមក្នុងអង្គពិធីនាពេលនេះនិងបានផ្តល់អនុសាសន៏ជូនដល់អង្គពិធីទាំងមូលពីបច្ចុប្បន្នភាពទូទៅរបស់ខេត្តព្រះវិហារជាពិសេស បញ្ហាដែលពាក់ពន្ធ័នឹងវិស័យសុខាភិបាលនិងប្រកាសបើកយុទ្ធនាការចែកមុងជ្រលក់ថ្នាំជូន

ដល់ ប្រជាពលរដ្ឋគោលដៅ និង ប្រជាជនចល័ត ដោយបានធ្វើការផ្ដាំផ្ញើរដល់ប្រជាពលរដ្ឋទាំងអស់ឱ្យចេះការពារខ្លួនពីជំងឺគ្រុនចាញ់ និងគោរពតាមការណែនាំរបស់មន្ត្រីសុខាភិបាលខេត្តដើម្បីរួមចំណែក លុបបំបាត់ជំងឺគ្រុនចាញ់ឱ្យអស់នៅឆ្នាំ ២០២៥ តាមផែនការយុទ្ធសាស្ត្រជាតិលុបបំបាត់ជំងឺគ្រុនចាញ់របស់រាជរដ្ឋាភិបាលឱ្យទទួលបានជោគជ័យ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១៨ ខែ កម្ភៈ ឆ្នាំ ២០១២

| | | |
|---|---|---|
| បានឃើញ និង ឯកភាព | បានឃើញ និង ពិនិត្យត្រឹមត្រូវ | អ្នកធ្វើរបាយការណ៍ |
| វេជ្ជ. ច ម៉េងចូ | វេជ្ជ. ហេង ពិសាល | លោកស្រីឱសថ.ម៉ម បូរ៉ាវ៉ាន់ |







